មានពីរភាសា ខ្មែរ និង អង់គ្លេស មានរូបភាពចំនួន ០៦ 06 images

**សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ ស្នើ ប្រមុខរដ្ឋាភិបាលខ្មែរដោះស្រាយបញ្ហាព្រំដែនកម្ពុជា-វៀតណាម នូវប្រាំចំណុច ខាងក្រោម៖**

KKC & KYAD request the Cambodian government to resolve Cambodia-Vietnam borders issue with the following 5 points:

១. លុបចោលសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥។ ដោយយើងខ្ញុំយល់ឃើញថា បញ្ហាដែលនៅតែមាន ហើយបន្តកើតមាន គឺដោយសារថា ពេលធ្វើច្បាប់នេះពុំមានការឯកភាពផ្ទៃក្នុងជាតិ។ មានន័យថា ពុំបានផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ ទាំងសង្គមមិនមែនរដ្ឋាភិបាល ទាំងគណបក្ស នយោបាយដែលអាចទទួលយកបានទាំងអស់គ្នា ជាពិសេសគណបក្សប្រឆាំងនៅក្នុងសភាពេលនោះបានប្រឆាំងដាច់អហង្កា និងដើរចេញពីអង្គប្រជុំសភាទៀតផង។

២.បង្កើតឧត្តមក្រុមប្រឹក្សាជាតិព្រំដែន ដែលមានព្រះមហាក្សត្រប្រថាប់ជាប្រធាន។

៣.លាតត្រដាងឯកសារ និង ផែនទីពាក់ព័ន្ធប្រទេសទាំងពីរកម្ពុជា-វៀតណាម ជាសាធារណៈ។

៤.ស្នើអន្តរាគមន៍ពីភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីអំពី បញ្ហាកម្ពុជា។ ព្រោះកិច្ចព្រមព្រៀងនេះ បានធានាច្បាស់លាស់ចំពោះឯករាជ្យ និង បូរណភាពទឹកដីខ្មែរ។

៥.ប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ។ នេះជាជម្រើសចុងក្រោយ។

KKC & KYAD request the Cambodian government to resolve Cambodia-Vietnam borders issue with the following 5 points:

1. Repeal the 2005 Supplemental Borders Treaty [between Cambodia and Vietnam]. We think the problems that remain, and continue to occur are because when there is no internal consensus at the time of the draft bill. It means that the draft bill was not widely and openly

publicized and both the civil society and political parties were not consulted that all parties can accept, especially the opposition in Parliament then vehemently opposed the draft bill and walked out of the National Assembly.

2. Establish the Supreme National Borders Council with the King as chair.

3. Disclose to the public on documents and maps concerning the two countries, Cambodia and Vietnam.

4. Request an intervention from signatory member countries of the Paris Peace Accord on Cambodia with regard to the issue. This agreement ensures precise Cambodia's independence and territorial integrity.

5. Appeal to (File law suit with) the International Court of Justice (ICJ). This is the last option.



# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ ៤៣ / ១៥ ស.ខ.ក.ក.

**គោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើ ដំណោះស្រាយបញ្ហាព្រំដែនកម្ពុជា-វៀតណាម

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមអនុញ្ញាតជំរាបជូនសម្តេចនាយកមេត្តាជ្រាបថា តាមប្រភពព័ត៌មានច្បាស់ការ និងតាមការចុះពិតនិត្យមើលជាក់ស្តែងរបស់អ្នកតំណាងរាស្ត្រ ព្រះសង្ឃ យុវជន ប្រជាពលរដ្ឋ និងអង្គការ-សមាគមនានា នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាមនាពេលថ្មីៗនេះ បានឃើញជាក់ស្តែងថា វៀតណាមកំពុងតែឈ្លានពានទន្ទ្រានចូលយកទឹកដីខ្មែរជាបន្តបន្ទាប់ ដោយគ្មានកោតក្រែង។ ដូចជានៅ៖

-ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជិតបង្គោលព្រំដែនលេខ៩៥។

-ក្រុមបច្ចេកទេសគណៈកម្មាធិការព្រំដែនកម្ពុជានិងអាជ្ញាធរខេត្តរតនគិរី បានរកឃើញស្រះចំនួន ៣បន្ថែមទៀតនៅក្នុងព្រៃជ្រៅបន្ទាប់ពីការរកឃើញមុននេះចំនួន៥ ដែលវៀតណាមបានជីកចន្លោះបង្គោលព្រំដែនលេខ៣០និងលេខ៤០ ក្នុងភូមិឡំ ឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ដែលកន្លែងនោះមិនទាន់បានកំណត់ព្រំដែនច្បាស់លាស់នៅឡើយ ។ ស្រះទឹកទី១មានទំហំ១២ម៉ែត្រគុណនឹង១៨ម៉ែត្រ ស្រះទឹកទី២មានទំហំ១៤,៥ម៉ែត្រគុណនឹង១៧ម៉ែត្រ និងស្រះទឹកទី៣
មានទំហំ១០ម៉ែត្រគុណនឹង២៤,៥ម៉ែត្រ ។

-នៅខេត្តកណ្តាល វៀតណាមកំពុងជីកដីធ្វើគ្រឹះសម្រាប់សាងសង់ប៉ុស្តិ៍យោធា ត្រង់ចំណុចនិយាមការ WT-06065-07703 នៅជាប់ភូមិព្រែកស្បូវ ក្នុងឃុំសំពៅពូន ស្រុកកោះធំ ។

-ខេត្តស្វាយរៀង បង្គោលលេខ១៩៧ វៀតណាមបានធ្វើផ្លូវធំទំហំ៣០ម ជាប់បង្គោលព្រំដែនក្នុងឃុំចន្ទ្រា ស្រុក ចន្ទ្រា ។ បង្គោលលេខ១៩៨ ឃុំថ្នាធ្នុង ស្រុករំដួល។ នៅឃុំថ្នង ស្រុករមាសហែក។ ភូមិធ្លក ឃុំត្នោត ស្រុកកំពង់រោទ៍ ជាដើម។

ដោយមិនអាចអត់ធ្មត់ចំពោះទង្វើឈ្លានពានម្តងហើយម្តងទៀតនេះបាន យើងបានឃើញក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្ញើលិខិតកំណត់ការទូតជូនរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន១០លើករួចហើយ ប៉ុន្តែភាគីវៀតណាមមិនបានឆ្លើយតបអ្វីឡើយ។ យើងខ្ញុំ សូមគោរព និងគាំទ្រពេញទំហឹងចំពោះជំហររដ្ឋាភិបាល និងសូមឲ្យបន្តការតវ៉ាបែបនេះជាបន្តទៀត។

ទីស្នាក់ការផ្ទះលេខ: ៧២ ផ្លូវលេខ: ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ៩៣ ៩៧ ៩៧ ០៦
E-mail: thachsetha13@gmail.com Website: http//www.khmerkromngo.org

ដើម្បីចូលរួមចំណែកក្នុងការរកដំណោះស្រាយបញ្ចប់បញ្ហាព្រំដែនកម្ពុជា-វៀតណាម ឲ្យក្លាយទៅជាព្រំដែនសន្តិភាព គោរពគ្នាទៅវិញទៅមកក្នុងឋានៈប្រទេសជិតខាងល្អ សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមស្នើសម្ដេចប្រធាន៖

១- លុបចោលសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥។ ដោយយើងខ្ញុំយល់ឃើញថា បញ្ហាដែលនៅតែមានហើយបន្តកើតមាន គឺដោយសារថា ពេលធ្វើច្បាប់នេះពុំមានការឯកភាពផ្ទៃក្នុងជាតិ។ មានន័យថាពុំបានផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងពិគ្រោះយោបល់ឲ្យបានល្អិតល្អន់ ទាំងសង្គមស៊ីវិលទាំងគណបក្សនយោបាយដែលអាចទទួលយកបានទាំងអស់គ្នា ជាពិសេសគណបក្សប្រឆាំងនៅក្នុងសភាពេលនោះ បានប្រឆាំងដាច់អហង្កា និងដើរចេញពីអង្គប្រជុំសភាទៀតផង។

២- បង្កើត ឧត្ដមក្រុមប្រឹក្សាជាតិព្រំដែន ដែលមានព្រះមហាក្សត្រប្រថាប់ ជាប្រធាន។

៣- លាតត្រដាងឯកសារ និងផែនទីពាក់ព័ន្ធប្រទេសទាំងពីរកម្ពុជា-វៀតណាមជាសាធារណៈ។

៤- ស្នើអន្តរាគមន៍ពីភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារិស ស្ដីអំពីបញ្ហាកម្ពុជា។ ព្រោះកិច្ចព្រមព្រៀងនេះ បានធានាច្បាស់លាស់ចំពោះឯករាជ្យនិងបូរណភាពទឹកដីខ្មែរ។

៥- ប្ដឹងទៅតុលាការយុត្តិធម៌អន្តរជាតិ។ នេះជាជម្រើសចុងក្រោយ។

សេចក្ដីដូចបានជំរាបជូនខាងលើ សូមសម្ដេចនាយកមេត្តាពិនិត្យនិងចាត់ការតាមនីតិវិធីតាមការគួរ សូមសម្ដេចនាយករដ្ឋមន្ត្រីទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ភ្នំពេញ,ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និង
សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ

ថាច់ សេដ្ឋា
អតីតសមាជិកព្រឹទ្ធសភា







សហគមន៍ខ្មែរកម្ពុជាក្រោម KKC KhmerKromngo.org